- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ .– តែងតាំងលោក **ឈឹម ទាន់** ជាប្រធាននាយកដ្ឋានសុរិយោដី នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ .– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ននិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

××××××

អនុក្រឹត្យលេខ : ២១៦ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

_បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_តាមសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ ._តែងតាំងលោក **ហួន សាវ៉ាង** ជាប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ ._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ននិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

XXXXXX

អនុក្រឹត្យលេខ : ២១៧ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣.
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ។

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងអស់លោកចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម ៖

១-លោក **សុខ សំបូរ** ជាបេសកជនពិសេសរបស់រាជរដ្ឋាភិបាលប្រចាំក្រុមហ៊ុនសម្បទានចំណតយន្តហោះ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២-លោក **ម៉ិន នី** ជានាយកអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

២_ សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

សេចក្តីសំរេចលេខ ៤៣ សសរ.

ស្តីពីការផ្គត់ផ្គង់ឱសថ និងសំភារៈបរិក្ខារពេទ្យ

ជូនក្រសួងសុខាភិបាល និងក្រសួងការពារជាតិ

*****

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ដែល ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

_យោងលិខិតលេខ ២២២៦ សហវ.ខ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំផ្គត់ផ្គង់ឱសថ និងសំភារៈបរិក្ខាពេទ្យជូនក្រសួងសុខាភិបាល និងក្រសួងការពារជាតិរបស់ក្រុមហ៊ុនសូគីម៉ិច ។

_យោងតាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ និងការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាត និងប្រគល់សិទ្ធអោយក្រុមហ៊ុនសូគីម៉ិច ក្នុងការធានាផ្គត់ផ្គង់ឱសថ និងសំភារៈបរិក្ខារពេទ្យជូនក្រសួងសុខាភិបាល និងក្រសួងការពារជាតិ ។

ប្រការ ២ : ក្រុមហ៊ុនសូគីម៉ិច ត្រូវធ្វើការផ្គត់ផ្គង់ឱសថ និងសំភារៈបរិក្ខារពេទ្យ ជូនក្រសួងសុខាភិបាល និងក្រសួងការពារជាតិដោយមិនត្រូវស្នើសុំរូបិយប័ណ្ណរបស់រដ្ឋទៅតំកល់ទុក សំរាប់បើកសារ

ឥណទានទេ ។ ចំពោះការទូទាត់សងបំណុលទៅអោយក្រុមហ៊ុនសូគីម៉ិច ត្រូវអនុវត្ត សងជាដំហាន១ តាមលទ្ធភាពថវិការដ្ឋ គិតជាប្រាក់រៀល តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៅថ្ងៃទូទាត់ ។

ប្រការ ៣ : ចំពោះថ្លៃឱសថ និងសំភារៈបរិក្ខារពេទ្យ ដែលមានចែងក្នុងប្រការ ១ ខាងលើ ក្រសួងសុខាភិបាល និងក្រសួងការពារជាតិ រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិគ្រោះថ្លៃ ជាមួយក្រុមហ៊ុនសូគីម៉ិច ជាបន្តបន្ទាប់អោយបានត្រឹមត្រូវ ។

ប្រការ ៤ : ក្រុមហ៊ុនសូគីម៉ិចត្រូវពិភាក្សា និងចុះហត្ថលេខាលើកិច្ចសន្យាលំអិតជាមួយក្រសួងសុខាភិបាល និងក្រសួងការពារជាតិ អំពីបរិមាណ និងយថាប្រភេទឱសថ និងសំភារៈបរិក្ខារពេទ្យ តាមដំណាក់កាលនិមួយ១ ហើយត្រូវចាប់ផ្តើមអនុវត្តការផ្គត់ផ្គង់ពីខែ មករា ឆ្នាំ ១៩៩៨ តទៅ ។

ប្រការ ៥ : លិខិតលេខ ៨៣៣ សជណ ផ.ស ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការផ្គត់ផ្គង់ឱសថ និងសំភារៈបរិក្ខាពេទ្យ ជូនក្រសួងសុខាភិបាល ក្នុងផែនការឆ្នាំ ១៩៩៦-១៩៩៧ និងឆ្នាំ ១៩៩៨ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនសូគីម៉ិច ត្រូវអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

****

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៩៤ សសរ

ស្តីពីការបង្កើតតំបន់ឃ្លាំងស្តុកប្រេងឥន្ធនៈ

ដោយព្យួរពន្ធនៅក្រុងព្រះសីហនុ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ដែល ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងលិខិតលេខ ២២ សហវ.ខ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំពិនិត្យសំរេចលើគំរោងបង្កើតតំបន់ពោងសំរាប់ស្តុកប្រេងមិនបង់ពន្ធ (ដោយព្យួរពន្ធ) របស់ក្រុមហ៊ុនសូគីមិច ។
- ក្នុងគោលដៅអនុវត្តគោលនយោបាយ លើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនឯកជនក្នុងស្រុក ។
- យោងតាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ និងការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាត និងប្រគល់សិទ្ធអោយក្រុមហ៊ុនសូគីម៉ិច បង្កើតតំបន់ឃ្លាំងស្តុកប្រេងឥន្ធនៈដោយព្យួរពន្ធនៅក្រុងព្រះសីហនុ ដែលមានទីតាំងនៅមណ្ឌលឃ្លាំងស្តុកប្រេងឥន្ធនៈរបស់ក្រុមហ៊ុនសូគីម៉ិច ស្ថិតក្នុងខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ។

ប្រការ ២ : តំបន់ឃ្លាំងស្តុកប្រេងឥន្ធនៈដោយព្យួរពន្ធនៅក្រុងព្រះសីហនុ ប្រើប្រាស់សំរាប់តែស្តុកផលិតប្រេងឥន្ធនៈ ដែលនាំចូលដោយមិនទាន់បានបង់ពន្ធ និងត្រូវធ្វើអាជីវកម្មចែកចាយក្នុងក្របខ័ណ្ឌ :

–ផ្គត់ផ្គង់បំពេញតំរូវការប្រើប្រាស់ក្នុងស្រុកផ្គត់ផ្គង់អោយនាវាសមុទ្រ និងធ្វើការនាំចេញបន្ត

ប្រការ ៣ : ការគ្រប់គ្រង និងការប្រមូលពន្ធលើប្រេងឥន្ធនៈនាំចូលនៅតំបន់ឃ្លាំងស្តុកប្រេងឥន្ធនៈដោយព្យួរពន្ធនៅក្រុងព្រះសីហនុ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ ៤ : ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងផ្តល់ផលប្រយោជន៍ទៅវិញទៅមក ក្រុមហ៊ុនសូគីម៉ិច ត្រូវអនុវត្តនូវលក្ខ័ណ្ឌមួយចំនួនដូចតទៅ :

–ត្រូវធានានូវបរិមាណប្រេងឥន្ធនៈ ដែលធ្លាប់បាននាំចូលកន្លងមក សំរាប់ប្រើប្រាស់ក្នុងប្រទេស ដើម្បីធានាអោយបាននូវប្រាក់ពន្ធ ចៀសវាងការថយចុះក្រោយពេលបង្កើតតំបន់ឃ្លាំងស្តុកប្រេងឥន្ធនៈដោយព្យួរពន្ធនៅក្រុងព្រះសីហនុ ។

–ត្រូវបង្កើតតំបន់ស្តុកប្រេងពីរអោយដាច់ពីគ្នា សំរាប់ស្តុកប្រេងឥន្ធនៈដែលបានបង់ពន្ធរួច និងប្រេងឥន្ធនៈដែលពុំទាន់បានបង់ពន្ធ ។

–ត្រូវធ្វើផែនការនាំចូលប្រេងឥន្ធនៈសំរាប់នាំចេញបន្ត និងសំរាប់លក់អោយនាវា នៅកណ្តាលសមុទ្រ ។

–ការធ្វើអាជីវកម្ម ការស្តុកប្រេងឥន្ធនៈ ត្រូវស្ថិតនៅក្រោមនីតិវិធី និងរបបភណ្ឌាគារគយ ។

–ត្រូវបង់កំរៃចំពោះប្រេងឥន្ធនៈ ដែលបាននាំចេញបន្ត និងប្រេងឥន្ធនៈដែលបានលក់អោយនាវានៅកណ្តាលសមុទ្រ ។

ប្រការ ៥ : មុននិងឈានទៅអនុវត្តជាក់ស្តែង ក្រុមហ៊ុនសូគីម៉ិចត្រូវធ្វើការពិភាក្សា និងចុះកិច្ចសន្យាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមច្បាប់ជាធរមាន ។

ប្រការ ៦ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមជាមួយ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដី ត្រូវមានវិធានការណ៍យ៉ាងម៉ឺងម៉ាត់បំផុត ក្នុងការលុបបំបាត់ អំពើរត់គេចពន្ធនៃការលួចនាំចូលប្រេងឥន្ធនៈ មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៧ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីរដ្ឋលេខាធិការ នៃក្រសួង_ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ និងក្រុមហ៊ុនសូតឺម៉ិច ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

× × × ×

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៤៥ សសរ

ស្តីពីការផ្ទេរសិទ្ធិ

****

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

_បានឃើញច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៧ ។

_យោងតាមការចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ឈាវ ឌី តាន់** អគ្គលេខាធិការរាជរដ្ឋាភិបាល ជាសហរដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសឯកឧត្តម **ទេព សេរីវុឌ្ឍន៍** ដែលអវត្តមានជាច្រើនខែកន្លងមក ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៤៦ សសរ

ស្តីពីការតែងតាំងទីប្រឹក្សារបស់នាយករដ្ឋមន្ត្រីទាំងពីរ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០១៩៤.២៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់លោកឧកញ៉ា គង់ ឫទ្ធីជព្វ ។

សំរេច

ប្រការ ១ : តែងតាំងលោកឧកញ៉ា **គង់ ឫទ្ធីជព្វ** ជាទីប្រឹក្សាខាងផ្នែកកីឡា អមនាយករដ្ឋមន្ត្រីទាំងពីរ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * * *

៣- សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ស្តីពីការរៀបចំគំរោងថវិការដ្ឋឆ្នាំ១៩៩៨

****

យោង : ច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងសារាចរលេខ ០៥ សសរ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាល ស្តីពីការណែនាំអំពីការរៀបចំគំរោងថវិកាប្រចាំឆ្នាំនីមួយៗ ។

រាជរដ្ឋាភិបាលសូមជំរាប ក្រសួង ស្ថាប័នទាំងអស់ អំពីសភាពការណ៍សេដ្ឋកិច្ច នៃឆ្នាំកន្លងមក និងសូមណែនាំលើការត្រៀមរៀបចំគំរោងថវិការដ្ឋឆ្នាំ ១៩៩៨ ខាងក្រោយនេះ ដោយឈរលើ បរិការណ៍(CONTEXTE) សេដ្ឋកិច្ចបច្ចុប្បន្ន និងការព្យាករណ៍ទៅអនាគតដូចតទៅ ៖

I-សេចក្តីផ្តើម :

ក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ត្រូវចាប់ផ្តើមរៀបចំគំរោងថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចធ្វើសារាចរណែនាំពីលក្ខណៈ បច្ចេកទេសស្តីពីការរៀបចំគំរោងថវិកាឆ្នាំ ១៩៩៨ ជាពិសេសកំណត់នូវនីតិវិធី និងបែបបទនៃការរៀបចំ ថវិកា ព្រមទាំងវិធានទាំងឡាយដែលត្រូវអនុវត្តក្នុងការគិតគូរគំរោងចំណូល និងគំរោងចំណាយនៃថវិកា ។

ថវិកាឆ្នាំ ១៩៩៨ ស្ថិតក្នុងក្របខ័ណ្ឌ នៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ១៩៩៦-២០០០ លើកទី១ ។ ឆ្នាំ ១៩៩៦ ដែលជាឆ្នាំទី១ នៃការអនុវត្តន៍ផែនការនេះ សំរេចបានលទ្ធផល ល្អក្នុងវិស័យសេដ្ឋកិច្ច ថ្វីត្បិតតែកំណើនសេដ្ឋកិច្ចសំរេចបានទាបជាងបន្តិចពីគំរោងដើមឆ្នាំក៏ដោយ ។ ឆ្នាំ ១៩៩៧ នេះ កំណើតសេដ្ឋកិច្ចប្រហែលជាមិនអាចសំរេចបានតាមការគ្រោងទុកទេ ។ ព្រឹត្តិការណ៍ថ្ងៃ១ នៅ ថ្ងៃទី០៥ និងទី ៦ ខែ កក្កដា ជះឥទ្ធិពលខ្លះដល់កំណើនសេដ្ឋកិច្ចសំរាប់ឆមាសទី២ ឆ្នាំ ១៩៩៧ ហើយ ឥទ្ធិពលអាចបន្តរហូតដល់ឆ្នាំ ១៩៩៨ ទៀត ។ ម្យ៉ាងទៀតឆ្នាំ ១៩៩៨ គឺជាឆ្នាំដែលត្រូវធ្វើការបោះឆ្នោត តំណាងរាស្ត្រ ។ ដូច្នេះមានការទាមទារចំណាយថែមខាងថវិការដ្ឋ ហើយឥទ្ធិពលចិត្តសាស្ត្រ មុខជានឹងធ្វើ អោយមានផលវិបាកប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច ។

ក្នុងបរិការណ៍ដូច្នេះ រាជរដ្ឋាភិបាលដែលជាអ្នកទទួលខុសត្រូវធានាអោយបាននូវតុល្យភាពម៉ាក្រូ សេដ្ឋកិច្ច និងជាអ្នកផ្តួចផ្តើមគំនិតជំរុញសកម្មភាពសេដ្ឋកិច្ចអោយបានសំរេចកំណើននោះ កំពុងស្ថិតនៅចំពោះ មុខការត្រូវបំពេញការងារដ៏ធំធេងណាស់ជាមួយអ្នកដើរតួរងទៀតនៃសេដ្ឋកិច្ចជាតិ ។ រាជរដ្ឋាភិបាល ត្រូវតែ មជ្ឈិតក្តាប់អោយជាប់នូវគោលដៅចំបងពីរ ទាំងខាងសេដ្ឋកិច ទាំងខាងផ្នែកសង្គម និងទាំងខាងហិរញ្ញវត្ថុ ។ គោលដៅចំបងពីរនោះគឺបន្ត កណែតម្រូវ (AJUSTEMENT) និងការធ្វើអោយសំរេចកំណើនសេដ្ឋកិច្ច ។

II-ទិន្នន័យ និងឧស្សុនៈទិស័យនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពីឆ្នាំ ១៩៩៦ ដល់ ១៩៩៨ :

II.១.សេដ្ឋកិច្ចជាតិនៅឆ្នាំ ១៩៩៦ : បានប្រព្រឹត្តទៅគួរជាទីពេញចិត្ត និយាយជារួម ថ្វីត្បិតតែមានការខ្វះ ខាតខ្លះ :

ក្រៅពីកំណើនពិតប្រាកដ នៃផលិតផលក្នុងស្រុក សរុប (ផសស)៦.៤១% មានទិន្នន័យ៤ ដែលបញ្ជាក់នូវសមិទ្ធិផលនៃការកសាងសេដ្ឋកិច្ចជាតិក្នុងឆ្នាំ ១៩៩៦ ។ ទិន្នន័យទាំង៤នោះគឺ ៖

ទី១.សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (CPI) ខ្ពស់បន្តិច ប៉ុន្តែរាជរដ្ឋាភិបាលគ្រប់គ្រងអតិផរណា បានអោយនៅត្រឹមតែ ៩% ។-

ទី២.ការនាំចូល ការនាំចេញ(សុទ្ធ)មានការវិវត្តន៍ឡើងដូចគ្នា គឺឡើងរៀង១ខ្លួន ១១.១% និង១០.៨%។

ទី៣.ឱនភាពជុលនៃតុល្យភាពចន្តរ ត្រូវបានរក្សាសឹងតែស្មើកិតឆ្នាំ ១៩៩៥ដែរ (គឺឡើងតែ+ ២.៣%)។

ទី៤.ទុនបំរុងបរទេសសរុបធានាបាន ២.១ ខែសំរាប់ការនាំចូល ។

រាជរដ្ឋាភិបាលទទួលស្គាល់ថា សមិទ្ធិផលនេះសំរេចបានដោយសារមានកត្តាពីបរទេសគឺ ៖

ទី១.ការផ្ទេរជាផ្លូវការក្រោមរូបភាពជាអំណោយឡើងទៅដល់ចំនួន ២៩៩.០ លានដុល្លាអាមេរិក ដែលជួយដោះកុនដល់ទៅ ៦១.៤% អោយឱនភាពដុល្លា នៃតុល្យភាពចរន្ត ។

ទី២.ការខ្ចីប្រាក់ពីបរទេសចំនួន ៥៦.០ លានដុល្លារអាមេរិក ។

ទី៣.វិនិយោគផ្ទាល់ពីបរទេស (FDI)ចំនួន ២៤០.០ លានដូល្លាអាមេរិក គឺឡើង +៥៨.៩% បើប្រៀប ធៀបទៅនឹងឆ្នាំ ១៩៩៥ ។

ប៉ុន្តែសមិទ្ធិផលឆ្នាំ ១៩៩៦ នេះក៏បានបង្ហាញថា រាជរដ្ឋាភិបាលគ្រប់គ្រងសេដ្ឋកិច្ចបានល្អដែរ :

ទី១.ខាងនយោបាយរូបិយវត្ថុ : មានការកើនឡើងខ្លាំងបង្គួរនៃចំនួនសាច់ប្រាក់ប្រើប្រាស់ (+៤០.៤%) ។ នេះមកពីទំហំប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (RATIO : ០,៦៣ ដោយប្រៀបធៀបទៅនឹងបរិមាណរូបិយវត្ថុ) ។

ទី២.អត្រាប្រាក់រៀល ដុល្លាអាមេរិក ប្រែប្រួលតែ ៦.៩ ប៉ុណ្ណោះគឺ (២.៧២០រៀលក្នុង១ដុល្លារ នៅដំណាច់ឆ្នាំ ១៩៩៥) ។

ការអនុវត្តន៍ថវិកានៅឆ្នាំ ១៩៩៦ បានបង្ហាញនូវការលំបាកមួយចំនួន ។ ពិតប្រាកដហើយឱនភាពថវិកាជាប្រចាំមានតែ–០.៩៧% ដោយប្រៀបធៀបទៅនឹងផសស ទល់នឹង–១.៣៤% នៅឆ្នាំ១៩៩៥។ ប៉ុន្តែចំណូលសារពើពន្ធនៅតែទាបនៅឡើយដោយប្រៀបធៀបទៅនឹង ផសស គឺបានតែ ៦.៥២% ។ ចំណែកឯការចំណាយវិញ ចំណាយលើប្រាក់បៀវត្សស្រុបអស់ចំនួន ៤.១៩% នៃ ផសស និងត្រូវជា ៤៣.៦% នៃចំណាយជាប្រចាំ ។ ចំណាយខាងការពារ និងសន្តិសុខនៅតែបន្តស្រុបជិតអស់ ៥% នៃផសស (៤.៥៦%) និងត្រូវជា ៥១.៥% នៃចំណាយជាប្រចាំទល់នឹង ២.១៩% នៃផសស និង ២២.៧% តែប៉ុណ្ណោះ នៃចំណាយជាប្រចាំសំរាប់ផ្នែកសង្គមទាំងមូល (នៅក្នុងនោះ ១.៥៥% នៃផសស និងត្រូវជា ១៥.៦ នៃចំណាយជាប្រចាំសំរាប់អប់រំ និងសុខាភិបាល) ។

II.2- សេដ្ឋកិច្ចជាតិឆ្នាំ ១៩៩៧ នេះនឹងមាននិន្នាការឆ្ពោះទៅរកធ្លាក់ចុះនៃកំណើន :

តាមគំរោងដើមឆ្នាំ ១៩៩៧ នេះ រាជរដ្ឋាភិបាលត្រូវបន្តគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចអោយបានល្អជាងឆ្នាំ ១៩៩៦ និងធ្វើអោយបានកំណើនសេដ្ឋកិច្ច ៦.៥% និងធ្វើអោយថវិកាជាប្រចាំលើសចំនួន ០.១៦%

នៃផសស ។ ប៉ុន្តែមានសញ្ញាជាច្រើនបង្ហាញអោយឃើញជាប្រផ្នូលថាឆ្នាំ ១៩៩៧ មិនមែនជាឆ្នាំដែលមានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ល្អប្រសើរទេ ។

ខាងសេដ្ឋកិច្ច បាតុភូតរាំងស្ងួត ទឹកជំនន់បានធ្វើអោយប៉ះពាល់ផលិតផលកសិកម្ម ។ នៅឆមាសទី១ សកម្មភាពខាងឧស្សាហកម្ម និងសេវាបានឈានទៅមុខទៀត ។ រាជរដ្ឋាភិបាលគ្រប់គ្រងអតិផរណាបាន (គឺ ៦,៣១% ដែលជាអត្រាសំរាប់ ៣ខែ រំកិលមកទល់ខែឧសភា ឆ្នាំ១៩៩៧) និងអត្រាប្រាក់រៀល_ដុល្លារអាមេរិកមានស្ថេរភាព (២,៧៦៤៛/ US) ។ ប៉ុន្តែខាងស្ថានភាពថវិកាវិញ ការអនុវត្តន៍ក្នុងឆមាសទី១ បានបង្ហាញ អោយឃើញមានការតឹងតែងយ៉ាងខ្លាំង ។ ការបាត់ចំណូលថវិកានៅឆមាសទី១ បូកព្រឹត្តិការណ៍ថ្ងៃទី ៥ ៦ ខែ កក្កដា ចំណូលថវិកាទូទាំងឆ្នាំ ១៩៩៧ ប្រហែលជានៅឯអាយ ២០% នៃគំរោងដើមឆ្នាំ ។

ដូច្នេះហើយបានរាជរដ្ឋាភិបាលបានបញ្ជាអោយរក្សាអោយបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច គឺត្រូវសំរេចអោយបាននូវតុល្យភាពចំណូល ចំណាយថវិកា ហើយភ្ជាប់អោយជាប់នូវវិន័យនេះ ដើម្បីអោយរាជរដ្ឋាភិបាលបន្តនូវភាពម្ចាស់ការ គ្រប់គ្រងស្ថានភាពសេដ្ឋកិច្ចអោយបាន និងចៀសវាងរាល់ការថ្លោះធ្លោយអោយបាន ។ ការគណនាសេដ្ឋកិច្ចឡើងវិញ ជាបឋមសំរាប់ឆ្នាំ ១៩៩៧ បានបង្ហាញអោយឃើញថាកំណើនសេដ្ឋកិច្ច និងស្រុតចុះនិងអោយឃើញនូវការយឺតយ៉ាវ ក្នុងការផ្ទេរមូលនិធិក្រៅប្រទេសមកក្នុងប្រទេស ។

II.៣_ភាពតានតឹងនេះនឹងអូសបន្លាយនៅឆ្នាំ ១៩៩៨ ជាហេតុធ្វើអោយប៉ះពាល់សេដ្ឋកិច្ចជាតិ

សេដ្ឋកិច្ចនៅឆ្នាំ ១៩៩៨ ត្រូវបានព្យាករណ៍អោយឃើញមានការថយចុះនៃផលិតកម្មវិនិយោគ និងទុនជាមូលនិធិសាធារណៈក្រៅប្រទេស និងមូលនិធិឯកជន ។ ភាពតានតឹងនឹងធ្វើអោយទំនិញឡើងថ្លៃ ធ្វើអោយប្រាក់រៀលហើម និងធ្វើអោយហិរញ្ញវត្ថុសាធារណៈមានការលំបាក ។ ភាពធូរស្រាលប្រហែលជានឹងកើតមានឡើងវិញបានឆមាសទី២ ឆ្នាំ១៩៩៨ ។ ប៉ុន្តែអត្រាកំណើនសេដ្ឋកិច្ចនៅតែទាប ។ សំទុះថ្មីនៅដំណាច់ឆ្នាំ ១៩៩៨ អាចជំរុញល្បឿនកំណើននៅឆ្នាំ ១៩៩៩ និងរហូតទៅដល់ឆ្នាំ ២០០០ ។ ដូច្នេះការខិតខំប្រឹងប្រែងរបស់ជាតិ គឺជាមូលដ្ឋាន ។ រាជរដ្ឋាភិបាលសុំអោយកែណ្ឌប្រមូលសក្តានុភាពរបស់ប្រទេសទាំងមូល សំរាប់អោយសំរេចទិសដៅនេះ ។

III- ច្បាប់ចង្អៀតនៃថវិកាជាតិសំរាប់ឆ្នាំ ១៩៩៨

រាជរដ្ឋាភិបាលកំណត់ថវិកាឆ្នាំ ១៩៩៨ ត្រូវជាថវិកាមួយសមហេតុសមផល ដែលគ្រប់ក្រសួងស្ថាប័នអាចទទួលយកបាន ដើម្បីធានាប្រក្រតីភាពនៃដំណើរការរដ្ឋបាលសាធារណៈ ។ ពីព្រោះវាត្រូវឆ្លុះបញ្ចាំងនូវគោលដៅពីរនៃនយោបាយជាតិដូចពោលខាងលើ គឺ កំណែតំរូវ និងកំណើនសេដ្ឋកិច្ច ។ គោលដៅនៃកំណែតំរូវទាមទារអោយមានការកែសំរួលជាបន្តបន្ទាប់នូវរចនាសម្ព័ន្ធនៃថវិកា ដើម្បីទប់ចំណាយសាធារណៈអោយស្ថិតនៅក្នុងក៏រិតធនធានដែលមាន ។ ធនធានទាំងនេះបានមកពីធនធានជាក់ស្តែងជាអចិន្ត្រៃយ៍ ដូចជា ពន្ធដារ ពន្ធគយ និងចំណូលពុំមែនសារពើពន្ធ ។ ដាច់ខាតមិនត្រូវមានចំណូលដែលបាន

មកពីការធ្វើហិរញ្ញប្ប ទានរូបិវត្ថុពីធនាគារជាតិ ។ ដាច់ខាតមិនត្រូវមានការបោះផ្សាយក្រដាស់ប្រាក់ ដោយគ្មានមូលនិធិបដិភាគ ។ យ៉ាងនេះទើបគ្រប់គ្រងអតិផរណាបាន ។ ត្រូវតែធ្វើអោយមានការបែងចែកឡើងវិញដែរនូវឥណទានថវិកាដើម្បីជា គុណប្រយោជន៍ដល់ផ្នែកជាអាទិភាព : គឺចំណាយសង្គម ជាអាទិ៍ចំណាយសំរាប់អប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។

ថវិការដ្ឋនឹងចូលរួមធ្វើអោយមានកំណើនសេដ្ឋកិច្ចជាបរិមាណ តាមរយៈការចាក់បញ្ចូលមូលនិធិទៅក្នុងសេដ្ឋកិច្ច គឺតាមរយៈចំណាយសាធារណៈ និងចំណាយវិនិយោគសាធារណៈ ដែលថវិការ៉ាប់រងផ្តល់ ។ យ៉ាងនេះ ថវិការួមជំរុញវិនិយោគជាតិ ។ ជាគុណភាពរាជរដ្ឋាភិបាលនឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច គឺរដ្ឋត្រូវបន្តជួយសំរួលវិនិយោគឯកជនអោយបានកាន់តែល្អ និងស្វាហាប់ ។ រដ្ឋត្រូវឧបត្ថម្ភរាល់សកម្មភាពជាតិ បំពេញច្បាប់លិខិតបទដ្ឋាន សំរួលបែបបទរដ្ឋបាល ពង្រឹងសន្តិសុខ និងជំរុញការកែទំរង់ ...។

រាជរដ្ឋាភិបាលកំណត់នូវទិន្នន័យនៃគំរោងថវិកាឆ្នាំ ១៩៩៨ ដោយប្រៀបធៀបទៅនឹង ផសស ឆ្នាំ១៩៩៨ ដូចតទៅ ៖

ក_ចំណូលក្នុងប្រទេស (១+២)	: ៨.២៦%
១_ចំណូលជាប្រចាំ	: ៨.០៩%
_ចំណូលសារពើពន្ធ	: ៥.៩៤
_ចំណូលពុំមែនសារពើពន្ធ	២.១២%
២_ចំណូលជាមូលធនក្នុងប្រទេស	: ០.១៧%
ខ_ចំណាយសរុប (១+២)	: ១២.៩៩%
១_ចំណាយជាប្រចាំ	: ៧.៧៤%
២_ចំណាយជាមូលធន(វិនិយោគ)	: ៥.២៤%
_វិនិយោគក្នុងប្រទេស	: ១.២៦%
_វិនិយោគក្រៅប្រទេសផ្ទាល់	: ៣.៩៨%
ឱនភាពជាប្រចាំ ឬចំនួនលើស	: +០.៣៥%
ឱនភាពសរុប	: -៤.៧៣%

នៅក្នុងក្របខ័ណ្ឌទិន្នន័យខាងលើនេះ ក្រសួងសេដ្ឋកិច្ច និហិរញ្ញវត្ថុ ត្រូវកំណត់ព្រំដែនថវិកា (Enveloppe budgetaire) សំរាប់ក្រសួង ស្ថាប័ននិមួយៗ អោយសមស្របទៅនឹងទិន្នន័យម៉ាក្រូសេដ្ឋកិច្ចហិរញ្ញវត្ថុ ។

បានទទួលសារាចរនេះហើយគ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវអនុវត្តអោយបានហ្មត់ចត់តាមកាលបរិច្ឆេទជាក់ជិត ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

****

III – ការងារបណ្តាក្រសួង

១–ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៩៩៦ តរ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀង ស្តីពីការវិនិយោគទុនរ៉ែ នៅតំបន់អូរយាដាវលើ-ក្រោម ខេត្តរតនគីរី ចុះ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៥ រវាងក្រុមហ៊ុន BREWER NATURAL RESCURCES DEVELOPMENT Co.Ltd និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញពាក្យស្នើសុំពន្យារអាជ្ញាប័ណ្ណស្វែងរុករកធនធានរ៉ែលើកទី២ របស់ក្រុមហ៊ុន ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៧

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យក្រុមហ៊ុន BREWER NATURAL RESOURCES DEVELOPMENT Co.Ltd មានអាស័យដ្ឋានផ្ទះលេខ ២៥៨ ផ្លូវ ១៥៦ សង្កាត់ទឹកល្អក់ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តធ្វើការសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែនៅតំបន់អូរយ៉ាដាវលើ-ក្រោម ខេត្តរតនៈគីរី លើផ្ទៃដី ៥០៤ គីឡូម៉ែត្រ ក្រឡា ដែលមានកូអរដោនេដូចតទៅ ៖

ចំណុច	ខ្សែរយៈបណ្តោយ	ខ្សែរយៈទទឹង
A	107°22'11"E	13°38'32"N
B	107°33'55"E	13°38'32"N
C	107°33'55"E	13°25'30"N
D	107°22'11"E	13°25'30"N

ប្រការ២ : ក្រុមហ៊ុនត្រូវដំណើរការធ្វើការស្វែងរុករកធនធានរ៉ែ លើផ្ទៃដីដែលបានកំណត់នេះដោយធានានូវលក្ខការណ៍ បច្ចេកទេស ភូគព្ភសាស្ត្រ ។

ប្រការ៣ : ប្រកាសនេះមានតំលៃដល់ខែតុលា ឆ្នាំ១៩៩៩ ។ ផុតកំណត់នេះ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណសិក្សាស្រាវជ្រាវស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូត វិញដោយឥតលក្ខខ័ណ្ឌ ។

ប្រការ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធានមន្ទីរទីស្តីការក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តរតនៈគីរី ប្រធានក្រុមហ៊ុន និងក្រុមការងារក្រសួង ត្រូវទទួលអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

ប្រការ៥ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ពូ សុធីរៈ

*****

២_នីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២១៨/៩៧ កធស.ប្រក

ស្តីពីការតែងតាំង មន្ត្រីរាជការ

*****

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣

_បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម.០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា

_បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

_បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែល រៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា

_បានឃើញលិខិតលេខ ១៩៧_៩៧ ម.ស.ខ.កក ចុះថ្ងៃទី ១៩_៩_១៩៩៧ របស់ មន្ទីរធម្មការ និង សាសនាខេត្តកោះកុង

_ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការ ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម ៖

១_លោក **ឱុន ឌី** បច្ចុប្បន្នអនុប្រធានការិយាល័យពុទ្ធិកសិក្សា
ជាប្រធានការិយាល័យពុទ្ធិកសិក្សា

២_លោក **សំ ចឿន** បច្ចុប្បន្នបុគ្គលិក ជាអនុប្រធានការិយាល័យរដ្ឋបាល

៣_លោក **វណ្ណា នូណាស់** បច្ចុប្បន្នអនុប្រធានការិយាល័យធម្មការនិងសាសនា
ជាប្រធានការិយាល័យ ធម្មការ និង សាសនា

ប្រការ២ : ប្រភេទកាំបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រគល់ជូនមន្ទីរធម្មការ និងសាសនាជាអ្នករៀបចំនិងរ៉ាប់រង។

ប្រការ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច ការិយាល័យបុគ្គលិក-ការិយាល័យគណនេយ្យ មន្ទីរធម្មការ និងសាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្តកោះកុង និងអស់លោកដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តរៀងៗខ្លួនតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខានិងត្រា

ហឿន វណ្ណារត្ន័

* * * * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២២១/៩៧ កធស.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

***

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣

_បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម.០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា

_បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ ន.ស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤

_បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា

_បានឃើញលិខិតលេខ ៨៩_៩៧ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៧ របស់មន្ទីរធម្មការ និង សាសនា

_អនុលោមតាមការចាំបាច់របស់ក្រសួង និង សមត្ថភាពរបស់មន្ត្រី

សម្រេច

ប្រការ១ : តែងតាំងលោក **ឡុច ស្មើ** បច្ចុប្បន្នទទួលគណនេយ្យ ជាប្រធានការិយាល័យរដ្ឋបាលបុគ្គលិក និងហិរញ្ញកិច្ច នៃមន្ទីរធម្មការ និងសាសនាខេត្តមណ្ឌលគិរី ។

ប្រការ២ : ប្រភេទកាំប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រគល់ជូនមន្ទីរធម្មការ និងសាសនាខេត្ត ជាអ្នករៀបចំ ចាត់ចែងនិងរាប់រង ។

ប្រការ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច ការិយាល័យបុគ្គលិក-ការិយាល័យគណនេយ្យ មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរផែនការខេត្ត មន្ទីរហិរញ្ញវត្ថុខេត្តមណ្ឌលគីរី និង លោក **ឡុច រស្មី** ត្រូវអនុវត្ត រៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ៤ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខានិងត្រា

ហឿន វណ្ណារត្ន័

* * * *

៣_ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៦០៣ សសរ.មស.ក្រខ

ស្តីពី

ការកែតំរូវសេចក្តីសំរេចលេខ ៥៨៣ សសរ មស ក្រខ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

*****

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

_បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

_បានឃើញព្រះរាជក្រឹត្យលេខ ជស រកត ០៨៩៧ ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ បក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

_យោងសេចក្តីសំរេច លេខ ៥៨៣ សសរ មស ក្រខ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សំរេច

ប្រការ១ : កែតំរូវតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចលេខ ៥៨៣សសរ មស.ក្រខ ចុះថ្ងៃទី២២ ខែ១០ ឆ្នាំ ១៩៩៧ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈដូចតទៅ ៖

លេខ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃ-ខែ ឆ្នាំកំណើត	អង្គភាពដើម។	មុខជំនាញបច្ចេកទេស	កំរិតបណ្តុះបណ្តាល	ប្រភពបណ្តុះបណ្តាល	កំរិត បៀវត្ស	អង្គភាពចូលបំរើការងារ
					ខ្ទឹមសារដើម				
៥	សៅ ឌូរ៉ាទិន	ប	២៦/១០/៦៥	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខI១	ទីស្តីការគណៈរដ្ឋមន្ត្រី
២៨	ម៉ែន សុវណ្ណសុខវុទ្ធិ	ប	០៣/៩/៧៣	សិស្ស	វិទ្យុទាក់ទង	ឧត្តម	សូវៀត	៩០%ខI១	ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
					ខ្ទឹមសារកែតម្រូវ				
៥	សៅ ឌូរ៉ាទី	ប	២៦/១០/៦៥	សិស្ស	ច្បាប់អន្តរជាតិ	ឧត្តម	សូវៀត	៩០%ខI១	ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
២៨	ម៉ែន សុវណ្ណសុខវុទ្ធិ	ប	០៣/៩/៧៣	សិស្ស	វិទ្យុទាក់ទង	ឧត្តម	សូវៀត	៩០%ខI១	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ប្រការ២ : រាល់ខ្លឹមសារផ្សេងៗពីប្រការខាងលើនេះ រក្សាទុកដដែល ។

ប្រការ៣ : អគ្គនាយកដ្ឋានមុខងារសាធារណៈ នាយកដ្ឋានត្រួតពិត្យរដ្ឋបាល និងការគ្រប់គ្រងមន្ត្រីរាជការ នាយកដ្ឋានក្របខ័ណ្ឌ សិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន មានភារកិច្ចអនុវត្ត សេចក្តីសំរេចនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

* * * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី

លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០០ រៀល